II-រាជរដ្ឋាភិបាលកម្ពុជា

១-អនុក្រឹត្យ

អនុក្រឹត្យ លេខ ០៦ អនក្រ.បក

ស្តីពី

ការលុបនាទីឡូត៍នេសាទ និងកាត់បន្ថយដែននេសាទ ក្នុងនាទីឡូត៍នេសាទ ខេត្តកណ្តាល ទុកសំរាប់ប្រជាពលរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញក្រឹត្យច្បាប់លេខ ៣៣ ក្រច ចុះថ្ងៃទី ០៩ ខែ មិនា ឆ្នាំ ១៩៨៧ ស្តីពីការគ្រប់គ្រងវិស័យជលផល
- បានអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃ ទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សំរេច

មាត្រា ១ .-

ត្រូវបានកែសំរួលប្រកាសលេខ ០០៨០ ប្រក.កសក ចុះថ្ងៃទី២៤ ខែ ឧសភា ឆ្នាំ ១៩៨៩ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការកំណត់ព្រំប្រទល់ នៃនាទីឡូត៍នេសាទ និងកន្លែងនេសាទ បំរុងទុកនៅទឹកសាប ក្នុងខេត្តកណ្តាលដូចតទៅ :

- លុបចេញនាទីឡូត៍នេសាទបឹងព្រែក លេខ ២ . ១៣. ១៤ និងលេខ ១៥ ចាប់ពីរដូវនេសាទ ឆ្នាំ ២០០១-២០០២ តទៅ ។
- កាត់ចេញពីនាទីឡូត៍នេសាទ នៃផ្ទៃដែននេសាទក្នុងខេត្តកណ្ដាល និងកំណត់ព្រំប្រទល់ឡូត៍នេសាទ ជាថ្មី ចាប់ពីពេលនេះតទៅ ដូចមាននៅក្នុងតារាងខាងក្រោម និងផែនទីភ្ជាប់ជាមួយ ។

តារាងស្ថិតិផ្ទៃឡូត៍នេសាទក្នុងខេត្តកណ្ដាល ដែលត្រូវលុប និងកាត់បន្ថយ

ឯកតា (ហិកតា)

ប្រភេទ និងលេខឡូត៍	ផ្ទៃឡូត៍ នេសាទ	ផ្ទៃឡូត៍ កាត់ចេញ	ផ្ទៃឡូត៍ នៅសល់	ផ្ទៃឡូត៍កាត់ គិតជាភាគរយ	ផ្សេងៗ
បឹងព្រែក					
១	៨ ៧៧២	៦ ៣២២	២ ៤៥០	៧២ ០០	
២	១៧ ២៥០	១៧ ២៥០	០	១០០	លុបចោល
៣	១២ ៨៦៩	១០ ១៥២	២ ៧១៧	៧៨ ៨៨	
៤	៩ ៦៤៨	៧ ៥១៥	២ ១៣៣	៧៧ ៩០	
៥	១០ ៥៩៦	៧ ៦៥៤	២ ៩៤២	៧២ ២៣	
៦	២៧ ៥៨០	១៨ ៣០០	៩ ២៨០	៦៦ ៣៥	
៧	៧ ៨៧០	៧ ០០៣	៨៦៧	៨៨ ៩៨	
៨	២ ៤០៥	១ ៨២៤	៥៨១	៧៥ ៨៤	
៩	៧ ១៦២	៤ ៥៨៥	២ ៥៧៧	៦៤ ០០	
១០	៣ ៧៦៨	១ ៣៣៤	២ ៤៣៤	៣៥ ៤០	
១១	៦ ៦៩៧	២ ៩១១	៣ ៧៨៦	៤៣ ៤៦	
១២	៩ ៨៤៩	៤ ១៦៧	៥ ៦៨២	៤២ ៣០	
១៣	៣ ៥២២	៣ ៥២២	០	១០០	លុបចោល
១៤	៦ ៤៥០	៦ ៤៥០	០	១០០	លុបចោល
១៥	១ ៥៥២	១ ៥៥២	០	១០០	លុបចោល
១៦	១២ ៣២២	៧ ៧៣៧	៤ ៥៨៥	៦២ ៧៩	
១៧	៩ ០៨៤	៦ ២៤៧	២ ៨៣៧	៦៨ ៧៦	

១៨	១២ ៨២៩	៧ ៣២៧	៥ ៥០២	៥៧ ១១	
១៩	៩ ៥០៣	៦ ២៣៦	៣ ២៦៧	៦៥ ៦២	
សរុប ១៩	១៧៩ ៧២៨	១២៨ ០៨៨	៥១ ៦៤០	៧១ ២៦	

មាត្រា ២ ..

ដែននេសាទដែលបានលុបចោល និងកាត់ចេញពីនាទីឡូត៍នេសាទ ត្រូវប្រគល់ជូន ប្រជាពលរដ្ឋប្រកបរបរ នេសាទគ្រួសារ ហាមដាច់ខាតមិនអោយជនណាមួយហ៊ុងហែងយកទៅលក់ ឬ ជួលអោយឯកជនធ្វើអាជីវកម្មផ្តាច់មុខឡើយ ។

មាត្រា ៣ ..

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវរៀបចំសហគមន៍នេសាទ ដើម្បីគ្រប់គ្រងកន្លែងដែលបានលុប និងកាត់ចេញពីនាទីឡូត៍នេសាទ នេះ ។

មាត្រា ៤ ..

រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៥ ..

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ភ្នំពេញ.ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១

នាយករដ្ឋមន្ត្រី

ហត្ថលេខានិងត្រា

ហ៊ុន សែន